# បុណ្យចូលឆ្នាំ

បុណ្យចូលឆ្នាំ គឺជាពិធីមួយដែលប្រជាជន ក្នុងពិភពលោកតែងតែប្រារព្ធធ្វើទៅតាមកាលបរិច្ឆេទនិង ជំនឿទំនៀមទម្លាប់រៀងៗខ្លួន។ ចំណែកប្រជាជនខ្មែរ ដែលជាពុទ្ធសាសនិក ក៏មានពិធីចូលឆ្នាំនេះ តាំងពីបុរាណកាល ពីយូរយារណាស់មកហើយដែរ។

## បុព្វហេតុនៃបុណ្យចូលឆ្នាំ

បានជាអ្នកប្រាជ្ញកំណត់ឱ្យមានពិធីចូលឆ្នាំ ឬបុណ្យចូលឆ្នាំប្រយោជន៍ ដើម្បីឱ្យមនុស្សគ្រប់រូបត្រូវចេះគិតពិចរាណក្នុងជីវិតរបស់ខ្លួនថា " តើក្នុងរយៈពេល១ឆ្នាំកន្លងមកនេះ ខ្លួនអញបានធ្វើអ្វីខ្លះ? អំពើដែលខ្លួនអញបានធ្វើនោះល្អឬអាក្រក់ បើគិតទៅឃើញថា អំពើដែលខ្លួនបានធ្វើនោះជាអំពើអាក្រក់ត្រូវលះបង់ចេញហើយ ត្រូវបំពេញនូវអំពើល្អវិញ តែបើពិចារណាទៅឃើញថា ជាអំពើល្អត្រូវ តែបន្តនូវអំពើល្អនេះតទៅទៀត"។ ហើយពិធីចូលឆ្នាំ ឬ បុណ្យចូលឆ្នាំនេះ ជាកថាខ័ណ្ឌមួយសំខាន់ចាំ បាច់ជាទីបំផុត សំរាប់ជីវិតរបស់មនុស្សគ្រប់រូប ក្នុងការងារ ១ ឆ្នាំនេះជាបទពសោធន៍សំរាប់យើង ហើយត្រូវចេះប្រមើលមើលទៅក្រោយ គឺមើលកិច្ចការ ដែលយើង បានធ្វើកន្លងមក។ ត្រូវចេះដកស្រង់យកចំណុចល្អៗសំរាប់បន្តនូវការងារថ្មីតទៅទៀត។ ហើយបុណ្យចូលឆ្នាំនេះ មានតាំង ពីជំនាន់ មុនសម័យពុទ្ធកាលមកម្លេះ។

## កាលកំណត់នៃបុណ្យចូលឆ្នាំខ្មែរ

កាលពីបុព្វសម័យ ខ្មែរយើងចាប់ផ្តើមធ្វើបុណ្យចូលឆ្នាំនៅក្នុងខែ មិគសិរ ព្រោះគេបានកំណត់យកខែនេះជាខែដើមឆ្នាំដោយហេតុថា ក្នុងសម័យ កាលនោះឆ្នាំនីមួយៗ លោកចែកជា ៣ រដូវទៅតាមចន្ទគតិគឺ : ហេមន្តរដូវ១, គិម្ហរដូវ១, និងវស្សានរដូវ,។ បុរាណាចារ្យយើងលោកគិតថាហេមន្តរដូវជារដូវមួយត្រជាក់ត្រូវចាត់ទុកជាដូវដើមឆ្នាំ ប្រៀបបានទៅនឹងពេលព្រឹកព្រហាម ដែល

ទើបកន្លងផុតពីរាត្រី គឺជាពេលខាងដើមនៃថ្ងៃ ។ គិម្ហរដូវជារដូវក្តៅចាត់ទុកជាកណ្តាលឆ្នាំ ប្រៀប បានទៅនឹងថ្ងៃត្រង់។ ឯវស្សានរដូវជារដូវ ដែលមានមេឃអួអាប់ងងឹតភ្លៀងធ្លាក់ច្រើន ត្រូវចាត់ទុកជា ចុងរដូវ ប្រៀបបានទៅនឹងពេលព្រលប់។ លុះចំណេរចិរកាលជាខាងក្រោយមកទៀត ពេលដែល បុព្វបុរសយើង និយមច្រើចុលួសករាជ ជាសំខាន់នោះគឺនៅក្នុងរជ្ជកាល នៃព្រះបាទសម្តេចព្រះ សិទ្ធពអមរិន្ទបរមព្រហ្មកិល "ពញាក្រែក" សម័យអង្គរពីចុងសតវត្សទី ១៤ ទើបកំណត់ចូលឆ្នាំថ្មី មានការផ្លាស់ប្តូរ ហើយក៏កំណត់យកខែចេត្រ ជាខែដើមឆ្នាំវិញ។ តែទោះបីជាយ៉ាងណាក៏ដោយ គេក៏នៅតែរាប់ខែមិគសិរជាខែទី ១ ដដែល។ ឯការបរិច្ឆេទថ្ងៃចូលឆ្នាំថ្មី គឺមិនឱ្យប្រព្រឹត្តទៅមុនថ្ងៃ ៤ កើត ខែចេត្រ និងមិនក្រោយថ្ងៃ ៤ កើត ខែ ពិសាខ ត្រូវនឹងថ្ងៃទី ១៣ ឬ ១៤ ខែមេសាដែរ។ ដោយការយល់ឃើញរបស់ចាសទុំខ្មែរយើងពីសម័យនោះលោកគិតថានៅមិគសិរប្រជាកសិករ យើងមានការមមាញឹកក្នុងរបរកសិកម្ម ម្លោះហើយនៅខែនេះកិច្ចការប្រមូលផលស្រូវក៏ត្រូវបាន បញ្ចប់សព្វគ្រប់ហើយដែរ ។ដោយសារតែប្រជាពលរដ្ឋយើងបានទទួលឥទ្ធិពលព្រះពុទ្ធសាសនា ពេល ដែលជនានុជនទំនេរគឺជាឱកាសមួយដ៏ល្អងាយស្រួលនឹងធ្វើបុណ្យសុន្ទរីទានកំសាន្តសប្បាយភ្ជាប់ទៅ នឹងប្រពៃ ណី ចូលឆ្នាំថ្មីរបស់ខ្លួនផង ។ ការកំណត់នេះ ក៏ជាប់ជាប្រវេណីរហូតមកដល់សព្វថ្ងៃនេះ ។

## ពិធីរៀបចំនៅមុនថ្ងៃចូលឆ្នាំ

នៅមុនថ្ងៃចូលឆ្នាំថ្មីជិតមកដល់ ប្រជាជនខ្មែរគ្រប់រូបបានត្រៀមទុក នូវសំលៀកបំពាក់ថ្មីៗ ត្រូវរៀបចំតុបតែងបោសសំអាតផ្ទះសម្បែង បោសសំអាតទីធ្លាវត្តអារាម តាមដងផ្លូវ ព្រះចេតិយ រមណីដ្ឋានសង់រានទេវតានៅតាមផ្ទះ ហើយរៀបទៀន ៥ ធូប ៥ ផ្កាភ្ញី ទឹកអប់ បារី ស្លា ម្លូ ផ្លែឈើ សម្រាប់បូជាទេវតាឆ្នាំថ្មី ដែលនឹងចុះមករក្សាមនុស្សលោកក្នុងឆ្នាំថ្មី ។

## ពិធីទទួលទេវតាឆ្នាំថ្មី

ថ្ងៃទី ១ គឺជាវារៈមហាសង្ក្រាន្ត ត្រូវចាំទួលទេវតាឆ្នាំថ្មី ពិធីចាំទទួលទេវតានេះ គឺជាពិធីមួយដែល ត្រូវចាប់ផ្តើមមុនគេបង្អស់នៃបុណ្យចូលឆ្នាំខ្មែរ ។ ពិធីទទួលទេវតានេះ បុព្វបុរស

ខ្មែរយើង ដែលធ្លាប់ បានធ្វើជាហូរហែមក គឺនៅមុនពេលមហាសង្ក្រាន្តឆ្នាំថ្មីចូលមកដល់ប្រមាណជា ៣០ ឬ ៤០ នាទី :

▪ នៅតាមវត្តអារាម ព្រះសង្ឃ និង ឧបាសក ឧបាសិកា បានរៀបចំទីកន្លែងមួយ នៅកណ្ដាលវាលក្នុងទីធ្លាវត្ត ពាសទៅដោយបារាំពណិ ។ ហើយមានរៀបគ្រឿងសក្ការៈផ្សេងៗ តុបតែងទៅដោយផ្កាភ្ញីរំយោលទង់ជាតិទង់សាសនា ។ ឧបាសក ឧបាសិកា ប្រដាប់ទៅដោយសំលៀកបំពាក់ស ។ ម្នាក់ៗមានទឹកមុខរីករាយ រំភើបក្នុងចិត្តជាទីបំផុត ចេញមកឈររង់ចាំទទួលទេវតាឆ្នាំថ្មី ។ ចំណែកព្រះសង្ឃវិញក៏និមន្តមកគង់នៅត្រង់កន្លែងដែលបានរៀបចំនោះដែរ ។ ដើម្បីចាំទទួលអបអរសាទរក្នុងការជូនដំណើរត្រឡប់ទៅវិញនៃទេវតាឆ្នាំចាស់ និងទទួលអបអរសាទរ ក្នុងការធ្វើដំណើរ ចុះមកថែរក្សាមនុស្ស នៃទេវតាឆ្នាំថ្មី ។ គ្រាន់តែដល់ពេលម៉ោង មហាសង្ក្រាន្តឆ្នាំថ្មីចូលមកដល់ភ្លាមសំឡេងបទភ្លេងពិណពាទ្យ ស្គរ រគាំង សំឡេងសូត្រធម៌ និងសំឡេងពរជ័យសាធុការ បានលាន់ឮយ៉ាងកងរំពង ចេញពីទីវត្តអារាម ។

▪ នៅតាមភូមិ ឬ ផ្ទះក៏មានសភាពដូចជានៅទីវត្តអារាមដែរ គឺនៅពេលដែលមហាសង្ក្រាន្តជិតចូលមកដល់ ។ បុរសស្ត្រី ចាស់ ក្មេង ក្រមុំ កំលោះ គេទាំងអស់គ្នាមានសភាពសប្បាយរីករាយស្រស់ស្រាយយ៉ាងក្រៃលែង បានរៀបចំតុបតែងខ្លួនប្រាណ ស្លៀកសំលៀកបំពាក់ចំរុះពណ៌ចេញមកឈរ នៅខាងក្រៅផ្ទះ ចាំទទួលទេវតាឆ្នាំថ្មី ដែលត្រូវចុះមកថែរក្សាមនុស្សលោក ។ លុះដល់មហា-សង្ក្រាន្តចូលមកដល់ លាន់ឮសំឡេងពរជ័យស័ព្ទសាធុការយ៉ាងអឺងកង ភ្លើងទៀនឆេះភ្លឺព្រោងព្រាតផ្សែងធូបបានហុយចេញពីរានទេវតាគ្រប់ៗផ្ទះ ។

រឿងដែលរង់ចាំទទួលទេវតាឆ្នាំថ្មីនេះ បុរាណាចារ្យយើងលោកយក ទៅតាមរឿងនិទានដែលមានមកក្នុង **មហាសំការសូត្រ** ថា : ក្នុងកាលខាងដើមនៃភទ្ទកប្បនេះ មានបុរសម្នាក់ឈ្មោះ " ធម្មបាល" ជាបុត្ររបស់សេដ្ឋីម្នាក់ ជាអ្នកមានចំណេះវិជ្ជា ដ៏វិសេសបានរៀនចប់ត្រៃវេទ តាំងតែពីអាយុ ៧ ឆ្នាំ ។ សេដ្ឋីបានសាងប្រាសាទ ឱ្យនៅទៀបដើមជ្រៃធំមួយស្ថិត នៅក្បែរមាត់ទន្លេ ដែលជាលំនៅរបស់បក្សាបក្សីទាំងឡាយ ។ **ធម្មបាល** ក៏បានចេះទាំងភាសាបក្សីនោះទៀតផង ។ ហើយបានជាអាចារ្យសំដែងនូវមង្គលផ្សេងៗ ដល់មនុស្សទាំងពួង ។ ព្រោះកាលនោះមនុស្សលោកតែងតែ

រាប់អាន **កបិលមហាព្រហ្ម** ថាជាអ្នកសំដែងមង្គលដល់មនុស្សទាំងពួងដែរ ។ **កបិលមហាព្រហ្ម** បានជ្រាបថា នៅឋានមនុស្សលោកមាន **ធម្មបាល** កុមារជាអ្នកពូកែសំដែងមង្គលមួយរូបដែរ។ ថ្ងៃមួយក៏បានចុះចាកទេវលោក មកសួរបញ្ហានឹង ធម្មបាល កុមារ ៣ ប្រស្នាគឺ :

📖 ប្រស្នាទី ១ តើវេលាព្រឹកសិរីរបស់មនុស្សឋិតនៅត្រង់ណា ?

📖 ប្រស្នាទី ២ តើវេលាថ្ងៃត្រង់សិរីរបស់មនុស្សឋិតនៅត្រង់ណា ?

📖 ប្រស្នាទី ៣ តើវេលាល្ងាចសិរីរបស់មនុស្សឋិតនៅត្រង់ណា ? ។ ក្រោយពីបានដាក់សំណួរនេះរួច យើងនឹងកាត់ក្បាលបូជា **ធម្មបាល** កុមារ ឯងបើដោះមិនរួចត្រូវកាត់ក្បាល **ធម្មបាល** កុមារឯងឱ្យយើងវិញ ។ ធម្មបាល កុមារនិយាយសុំឈប់បង្អង់ ៧ ថ្ងៃសិនដើម្បីនឹងគិតប្រស្នា ។ លុះពេលវេលាកន្លងទៅបាន ៦ ថ្ងៃហើយ ធម្មបាល នៅតែគិតរកចម្លើយប្រស្នានោះពុំឃើញដដែលហើយបានដឹងថា ព្រឹកនេះនឹងត្រូវស្លាប់ ដោយអាជ្ញារបស់ កបិលមហាព្រហ្ម ជាមិនខាន ។ ដូច្នេះគួរតែអញរត់ទៅពួនលាក់ខ្លួនឱ្យស្លាប់ ដោយខ្លួនឯងប្រសើរជាង ទើបចុះពីប្រាសាទទៅដេកពួននៅក្រោម ដើមឈើដ៏ធំ ១ ដែលមានម្លប់ត្រឈឹងត្រឈៃ ។ ឈើដែល មានម្លប់ត្រជាក់នេះ ជាទីស្នាក់អាស្រ័យនៅរបស់សត្វឥន្ទ្រីញី-ឈ្មោល ។ នៅក្នុងវេលាយប់នោះ ឥន្ទ្រី ញីសួរទៅឥន្ទ្រីឈ្មោលថា តើព្រឹកនេះយើងបានអាហារអ្វីស៊ី ? (ប៉ុន្តែក្បួនខ្លះថាកូនឥន្ទ្រីសួរមេវា) ឥន្ទ្រីឈ្មោលឆ្លើយថា យើងនឹងបានស៊ីសាច់ **ធម្មបាល** កុមារ ដែលត្រូវ កបិលមហាព្រហ្មសម្លាប់ ព្រោះដោះប្រស្នាមិនរួច ឥន្ទ្រីឈ្មោល បានប្រាប់សំណួរ និងចម្លើយដល់ឥន្ទ្រីញីថា :

❀ សំណួរទី ១ **កបិលមហាព្រហ្ម** បានសួរថា តើវេលាព្រឹកសិរិសួស្តី ស្ថិតនៅត្រង់ណាក្នុងខ្លួនមនុស្ស ? សំណួរនេះត្រូវឆ្លើយថា :

❀ វេលាព្រឹកសិរីសួស្តីស្ថិតនៅត្រង់មុខ ហេតុនេះមនុស្សម្នាក់ៗ ត្រូវយកទឹកមកលុបមុខនៅវេលាព្រឹកកុំខាន ។

❀ សំណួរទិ ២ **កបិលមហាព្រហ្ម** បានសួរថា តើនៅពេលថ្ងៃត្រង់ សិរីសួស្តីស្ថិតពៅត្រង់ណាក្នុងខ្លួនមនុស្ស ? សំណួរនេះត្រូវឆ្លើយថា :

- នៅវេលាថ្ងៃត្រង់សិរីសួស្តី ស្ថិតនៅត្រង់ដើមទ្រូង ។

ហេតុនេះ មនុស្សម្នាក់ៗ នៅវេលាថ្ងៃត្រង់ យកទឹកមកជូតលាងដើមទ្រូងកុំខាន ។

❀ សំណួរទី ៣ **បិលមហាព្រហ្ម** បានសួរថា តើនៅវេលាល្ងាចសិរីសួស្តីស្ថិតនៅត្រង់ណាក្នុងខ្លួនមនុស្ស ? សំណួរនេះត្រូវឆ្លើយថា :

- នៅវេលាល្ងាចសិរីសួស្តស្ថិតនៅត្រង់ជើង ។ ហេតុនេះមនុស្សម្នាក់ ៗ នៅវេលាល្ងាចត្រូវយកទឹកមកលាងជើង មុនពេលចូលដេកកុំខាន ។

ឯ **ធម្មបាល** កុមារលុះបានស្តាប់ឮដូច្នេះហើយ ក៏ត្រឡប់ទៅប្រាសាទវិញ ។ ពឹកឡើងកបិលមហាព្រហ្ម ក៏បានសួរប្រស្នា។ ពេលនោះ **ធម្មបាល** កុមារក៏បានឆ្លើយដោះស្រាយតាមដែលខ្លួនបានស្តាប់ឮនោះ។ ពាក្យពេចន៍ទាំងប៉ុន្មានរបស់ឥន្ទ្រី ក៏បានជាពន្លឺមកបំភ្លឺដោះស្រាយប្រស្នារបស់ **កបិលមហាព្រហ្ម** រួចហើយបានជៀសផុតពីក្តីមរណៈ ។ **កបិមហាព្រហ្ម** សុខចិត្តចាញ់ព្រមកាត់ក្បាលបូជា **ធម្មបាល** ។ មុននឹងកាត់ក្បាល **កបិលមហាព្រហ្ម** បានហៅទេពធីតា ៧ អង្គដែលជា បុត្រីរបស់ខ្លួនមកប្រាប់ថា ឥឡូវនេះបិតាត្រូវកាត់ក្បាលបូជា **ធម្មបាល** កុមារហើយ ។ តែក្បាលនេះ បើដាក់នៅលើផែនដី ក៏កើតទៅជាភ្លើងឆេះទាំងលោកធាតុ បើនឹងបោះទៅលើអាកាសភ្លៀងក៏រាំង បើនឹងបោះទៅក្នុងសមុទ្ទ ទឹកក៏នឹងរីងស្ងួតហួតហែងអស់គ្មានសល់មួយដំណក់ឡើយ។

ដូច្នេះសូមឱ្យកូនទាំង៧នាក់យកជើងពានមកទទួលក្បាលថាហើយក៏កាត់សិរសាហុចទៅឱ្យនាង **ទុង្សាទេវី** ជាកូនច្បងយកជើងពានមកទទួលសិរសាបិតា ហើយហែប្រទក្សិណភ្នំសុមេរុ ៦០ នាទីរួចហើយក៏អញ្ជើញព្រះសិរសានោះ ទៅប្រតិស្ឋានទុក ក្នុងមណ្ឌលនៅក្នុងគុហាកែវឈ្មោះ **ធម្មមាលី** នាភ្នំកៃលាស ហើយបូជាដោយគ្រឿងទិព្វផ្សេងៗ ដែលព្រះវិស្សុកម្មទេវបុត្តបាននិម្មិតដោយកែវទាំង ៧ ប្រការឈ្មោះ **ភគវតីសភា** ឱ្យជាទីប្រជុំនៃទេវបុត្ត ទេវតាទាំងឡាយ លុះដល់គម្រប់ឆ្នាំជាសង្ក្រាន្តហើយ នាងទេពធីតាទាំង ៧ អង្គ ក៏ផ្លាស់វេនគ្នាមកអញ្ជើញព្រះសិរសា **កបិលមហាព្រហ្ម** ដង្ហែប្រទក្សិណភ្នំព្រះ **សុមេរុ** រាល់ៗឆ្នាំ ។

## ឈ្មោះទេពធីតាទាំង ៧ អង្គ

១- បើសង្ក្រាន្តចំថ្ងៃអាទិត្យ ត្រូវវេននាង **ទុង្សាទេវី**

២- បើសង្ក្រាន្តចំថ្ងៃច័ន្ទ ត្រូវវេននាង **គោរាគៈទេវី**

៣- បើសង្ក្រាន្តចំថ្ងៃអង្គារ ត្រូវវេននាង **រាក្សសាទេវី**

៤- បើសង្ក្រាន្តចំថ្ងៃពុធ ត្រូវវេននាង **មណ្ឌាទេវី**

៥- បើសង្ក្រាន្តចំថ្ងៃព្រហស្បតិ៍ ត្រូវវេននាង **កិរិណីទេវី**

៦- បើសង្ក្រាន្តចំថ្ងៃសុក្រ ត្រូវវេននាង **កិមិរាទេវី**

៧- បើសង្ក្រាន្តចំថ្ងៃសៅរ៍ ត្រូវវេននាង **មហោទរាទេវី**

ដោយមាននិទានបែបនេះហើយ ទើបខ្មែរយើងមានជំនឿ ហើយរៀបចំពិធីទទួលទេវតាឆ្នាំថ្មី ដែលមកបីបាច់ថែរក្សាពិភពលោកទាំងមូលបូជាដោយគ្រឿងសក្ការៈទាំងលាយមានទៀនធូបភ្ញីផ្កា គ្រឿងក្រអូបផលាផលផ្សេងៗយ៉ាងឱឡារិកអធិកអធ័មជារៀងរាល់ឆ្នាំមិនដែលអាក់ខានឡើយ ។